# Long Beach Unified School District

## មន្ទីរអប់រំ ឡុងប៊ីច

### Hi Hill នៅ YMCA Camp Oakes

### កញ្ចប់ព័ត៌មានសំរាប់គ្រួសារ

**2026 - 2027**

កម្មវិធីសិក្សាផ្នែកខាងក្រៅសំរាប់ថ្នាក់ទី5
YMCA Camp Oakes
Big Bear City, CA

# តារាងមាតិកា

លិខិតពីអគ្គនាយក...........................................................................................................3

សេចក្តីសង្ខេបអំពីដំណើរសិក្សាទៅកាន់ Hi Hill នៅ YMCA Camp Oakes ........................................4

ព័ត៌មានទូទៅអំពី Hi Hill នៅ YMCA Camp Oakes ...............................................................5 - 6

គោលការណ៍ច្បាប់ និង នីតិវិធី ..................................................................................................7 - 9

បញ្ជីត្រួតពិនិត្យ មុននឹងចេញធ្វើដំណើរ...........................................................................................10

បញ្ជីឈ្មោះរបស់ដែលត្រូវរៀបដាក់ទៅជាមួយ...................................................................................11

Office of the Superintendent
1515 Hughes Way, Long Beach, CA 90810
(562) 997-8242

ខែឧសភា ឆ្នាំ2026

ជំរាបជូនគ្រួសារនៃសិស្សថ្នាក់បឋមសិក្សា និង TK-8 ជាទីគោរព

ខ្ញុំមានសេចក្តីរំភើបអំពីការជំរាបជូនលោកអ្នកថា ក្នុងមួយចំណែកនៃកម្មវិធីសិក្សារបស់មន្ទីរអប់រំ ឡុងប៊ីច គឺសិស្សរៀនថ្នាក់ទី ប្រាំ ទាំងអស់នឹងមានឱកាសចូលរួមពេញមួយសប្តាហ៍ជាមួយកម្មវិធីសិក្សាផ្នែកខាងក្រៅ (Outdoor Education) នៅ Camp Oakes ដែលស្ថិតនៅក្បែរទីក្រុង Big Bear នៃរដ្ឋ កាលីហ្វ័រញ៉ា ចាប់ផ្តើមក្នុងរដូវស្លឹកឈើជ្រុះ នៃឆ្នាំ2026 ខាងមុខនេះ។ ការធ្វើដំណើរសិក្សាទាំងអស់នេះ នឹងបន្តធ្វើតាមទំលាប់ពីពេលមុនៗមក ដែលបានចាប់ផ្តើមឡើងនៅក្នុងមន្ទីរអប់រំរបស់យើងក្នុងខែមេសា នៃឆ្នាំ1948 ដែលមានសិស្សទៅចូលរួម Camp Hi-Hill រាល់ឆ្នាំ។ គួរឱ្យសោកស្តាយ ដោយមូលហេតុថា នៅឆ្នាំ2010 គឺកម្មវិធីសិក្សាផ្នែកខាងក្រៅត្រូវបានបិទ។ ខ្ញុំមានសេចក្តីរីករាយ ដោយជំរាបជូនថា ក្រុមប្រឹក្សាភិបាលអប់រំរបស់យើងបានធ្វើការអនុម័តបង្កើតឡើងវិញនូវកម្មវិធីសិក្សាផ្នែកខាងក្រៅនៅ Camp Oakes តាមរយៈប្រើសេវាដ្ឋានរបស់ YMCA។

ការរៀបចំសំរាប់ដំណើរសិក្សាផ្នែកខាងក្រៅ មានរាប់បញ្ចូលទាំងការដឹកជញ្ជូនតាមរថយន្តក្រុងឈ្នួល ដែលការិយាល័យថ្នាក់លើជាអ្នកគ្រប់គ្រងលើការចំណាយផ្ទាល់។ ប៉ុន្តែ យើងខ្ញុំស្នើសុំលោកអ្នកឱ្យផ្តល់ជាព័ត៌មានចុះឈ្មោះដ៏ចាំបាច់ ដើម្បីបញ្ជាក់ថា ការរៀបចំដំណើរ គឺពិតជាមានភាពត្រឹមត្រូវមែនសំរាប់សិស្សរបស់លោកអ្នក។ សាលារៀននីមួយៗនឹងធ្វើការចេញដំណើរខុសថ្ងៃខែពីគ្នាទូទាំងឆ្នាំសិក្សា ហើយដូច្នេះ <u>សៀវភៅដៃ Hi Hill នៅ YMCA Camp Oakes សំរាប់គ្រួសារ</u> ត្រូវបានរៀបចំឡើងសំរាប់ធ្វើការបញ្ជាក់ថា ការទៅលេងដល់កន្លែងផ្ទាល់ នឹងនាំមកជាបទពិសោធន៍ដ៏ល្អមែនសំរាប់សិស្ស គ្រូបង្រៀន និងបុគ្គលិកប្រចាំមន្ទីរអប់រំ LBUSD ដែលនឹងទៅចូលរួមជាមួយ។ ដោយមានការគាំទ្រពីលោកអ្នក គឺខ្ញុំមានការជឿជាក់ថា ការធ្វើដំណើរសិក្សាពេញមួយសប្តាហ៍ទៅកាន់ភ្នំ នឹងនៅតែបន្តផ្តល់បទពិសោធន៍ដ៏មានអត្ថន័យសំរាប់សិស្សថ្នាក់ទី ប្រាំ របស់យើង ដើម្បីឱ្យពួកគេបង្កើនបាននូវចំណេះផ្នែកធម្មជាតិ និងវិទ្យាសាស្ត្រ រួមទាំងការជួយដល់ពួកគេផងអំពីការបង្កើននូវជំនាញទំនាក់ទំនង និងជំរៅទឹកចិត្តខ្ពស់សំរាប់ខ្លួនឯង។

ប្រសិនបើលោកអ្នកមានសំណួរ ឬក្តីកង្វល់ផ្សេងៗ គឺសូមទាក់ទងតាមទូរស័ព្ទ ឬអ៊ីម៉ែលទៅកាន់នាយកគ្រប់គ្រងកម្មវិធីសិក្សាផ្នែកខាងក្រៅ ប្រចាំការិយាល័យកម្មវិធីពង្រីកឱកាសសំរាប់ការសិក្សា។

ព័ត៌មានទាក់ទង គឺមាននៅតាម៖ https://www.lbschools.net/departments/elop/camp-hihill/camp-hihill-home។

ដោយសេចក្តីស្មោះ

Jill A. Baker, Ed.D
អគ្គនាយកសាលារៀន

LONG BEACH
UNIFIED SCHOOL DISTRICT
*Excellence & Equity*

the YMCA

## Hi Hill នៅ YMCA Camp Oakes - សេចក្តីសង្ខេបអំពីដំណើរសិក្សា

ការធ្វើដំណើរសិក្សាសំរាប់សិស្សថ្នាក់ទី ប្រាំ ទៅកាន់ Hi Hill នៅ YMCA Camp Oakes ត្រូវបានរៀបចំធ្វើតាមគំរោង ដែលជាចំណែកមួយនៃ ៉ការប្តេជ្ញាចិត្តរបស់មន្ទីរអប់រំ ឡុងប៊ីច ក្នុងការជួយយុវវ័យឱ្យទទួលបាននូវឱកាសជាសមធម៌សំរាប់ស្វែងយល់អំពីពិភពផ្សេងៗ ក្រៅតែពីសហគមនរស់នៅរបស់ពួកគេ។ ឱកាសនេះផ្តល់ឱកាសមួយសំរាប់សិស្សថ្នាក់ទី ប្រាំ ទាំងអស់ ដើម្បីរស់នៅ និងសិក្សាអំពីផ្នែកខាងក្រៅក្នុងរយៈពេលមួយសប្តាហ៍។ ការស្រាវជ្រាវបានបញ្ជាក់ថា កម្មវិធីសិក្សាផ្នែកខាងក្រៅ នាំមកជាប្រយោជន៍ដ៏ច្រើនចំណែកណាស់។ វាអាចជួយ**បង្កើននូវជំនឿទុកចិត្តចំពោះខ្លួនឯង ជំរៅទឹកចិត្តក្នុងខ្លួនឯង ជំនាញផ្នែកទំនាក់ទំនង ការនិយាយស្តី ទឹកចិត្តប្រឹងប្រែង និងជំនាញបញ្ចេញកំលាំងកាយ** ដែលគាំទ្រផ្នែកអាកប្បកិរិយា ដើម្បីឈានឆ្ពោះទៅកាន់ការសិក្សា និងការពង្រីកនូវសមត្ថភាពរបស់ខ្លួនសំរាប់បំពេញកិច្ចការជាសហការណ៍។

---

### តើសិស្សនឹងសិក្សាអំពីអ្វី

Hi Hill នៅ YMCA Camp Oakes ផ្តល់ឱកាសសិក្សាពិសេសសំរាប់កុមារ ដើម្បីជួប និងធ្វើសហការជាមួយសិស្សផ្សេងៗដូចគ្នា ដែលមានដើមកំណើតខុសពីគ្នា ហើយវានឹងជួយពួកគេបណ្តុះបាននូវជំនាញថ្មីក្នុងការរាប់អាន និងការធ្វើទំនាក់ទំនង ដែលនាំមកជាប្រយោជន៍សំរាប់ពេលរៀនក្នុងសាលា និងជារហូតតទៅ។ ការរស់នៅតាមបរិស្ថានសិក្សាចំនួន 24 ម៉ោងក្នុងមួយថ្ងៃ គឺសិស្សនឹងមានឱកាសបង្កើននូវការយល់ដឹង និងការបណ្តុះនូវទឹកចិត្តនៃគោលដៅតាមរយៈស្ថានភាពជាក់ស្តែងប្រចាំថ្ងៃ។ នៅតាម Hi Hill នៅ YMCA Camp Oakes គឺសិស្សទទួលមុខងារខុសត្រូវថ្មី ដោយចេះបង្ហាញនូវសេចក្តីគោរព និងទទួលស្គាល់តម្លៃមិត្តភាពរបស់មិត្តរួមថ្នាក់ និងគ្រូបង្រៀនរបស់ពួកគេតាមរយៈបទពិសោធន៍ផ្សេងៗជាសោភណភាព និងអ្វីផ្សេងទៀតដ៏អស្ចារ្យនៃផ្នែកធម្មជាតិខាងក្រៅ។ នៅសាលា ៉កម្មវិធីសិក្សាផ្នែកខាងក្រៅ គឺសិស្សរៀនយល់ផ្ទាល់តែម្តងអំពីគំនិតផ្នែកវិទ្យាសាស្ត្រ ដូចជា៖ ទេសភាព រុក្ខជាតិ និងសត្វព្រៃ ភូពួសាស្ត្រ ប្រភេទថ្ម និងរ៉ែ ហ្វូងផ្កាយ អាកាសធាតុ ប្រព័ន្ធទឹក និងអ្វីផ្សេងទៀតទាក់ទងតាមឱកាសសិក្សាជារបៀបដកពិសោធន៍ផ្ទាល់ដៃ។ ការសិក្សាផ្នែកខាងក្រៅ នាំមកនូវភាពរំភើប និងបទពិសោធនសំរាប់សិស្ស។ ដោយមូលហេតុនេះ សិស្សរៀនបានកាន់តែលឿន យល់ដឹងបានកាន់តែប្រសើរ និងរក្សាទុកចំណេះបានកាន់តែច្រើនអំពីអ្វី ដែលពួកគេបានរៀនមក។

នៅតាម Hi Hill នៅ YMCA Camp Oakes គឺមានសកម្មភាពកំសាន្តជាច្រើនសំរាប់សិស្ស ដែលរាប់បញ្ចូលដូចជា៖ ការបាញ់ធ្នូ គំនូរ និងវិស្វកម្ម ការស្ទូចត្រីល្បែងលេងជាក្រុម កីឡាបាល់ទះ ការស្រាវជ្រាវរុក្ខជាតិ ការដើរកំសាន្តកាត់ព្រៃភ្នំ ការជិះទូកកានូ ការលេងបាល់ ហ្គា ហ្គា ការតោងឡើងថ្ម ការលោតអន្ទាក់ ការរៀនសំគាល់ហ្វូងផ្កាយ និងការជួបជុំគ្នាក្បែរភ្នក់ភ្លើង ដែលអមដោយបទចម្រៀង និងការសើចសប្បាយជាមួយរឿងកំប្លែងខ្លីៗ រួមទាំងសកម្មភាពជាច្រើនផ្សេងទៀត។ ទាំងអស់នេះនឹងជួយសិស្សបង្កើននូវចំណេះរបស់ពួកគេ ជំរុញពួកគេឱ្យចេះធ្វើការតស៊ូ និងបំពេញកិច្ចការរួមគ្នាសំរាប់ការសិក្សាអំពីធម្មជាតិផ្នែកខាងក្រៅ។

Hi-Hill
at YMCA Camp Oakes
LBUSD

# Hi Hill នៅ YMCA Camp Oakes

# ព័ត៌មានទូទៅ

## ទីតាំងសេវាដ្ឋាន

កម្មវិធីសិក្សាផ្នែកខាងក្រៅរបស់មន្ទីរអប់រំ ឡុងប៊ីច គឺស្ថិតនៅ Long Beach YMCA’s Camp Oakes លើភ្នំ San Bernardino ក្បែរទីក្រុង Big Bear។ វាមានចំនួនផ្ទៃដីប្រមាណ 235 អេគ័រ ក្នុងឧទ្យានជាតិ San Bernardino National Forest ដែលមានកំពស់ 7,200 ហ្វីត។ Camp Oakes មានចម្ងាយប្រមាណ 120 ម៉ៃ ពីទីក្រុង Long Beach ឬ 15 នាទី ពីទីក្រុង Big Bear។

## ការចំណាយ

ការចំណាយសំរាប់ថ្លៃឈ្នួលនៅ Hi Hill នៅ YMCA Camp Oakes គឺនឹងចេញបង់ទាំងស្រុងដោយមន្ទីរអប់រំ ឡុងប៊ីច។ **គ្មានត្រូវការបង់ថ្លៃឈ្នួលទេសំរាប់ឱ្យសិស្សទៅចូលរួម**។ គ្រួសារ គឺជាអ្នកទទួលខុសត្រូវផ្នែកផ្តល់ជាសំលៀកបំពាក់ និងប្រដាប់គេងត្រឹមត្រូវសំរាប់សិស្សរបស់ពួកគេរៀបដាក់ទៅជាមួយ។ គ្រួសារទាំងឡាយណា ដែលត្រូវការជំនួយផ្នែកសំលៀកបំពាក់ ឬប្រដាប់គេង គឺគួរទាក់ទងទៅកាន់នាយកគ្រប់គ្រងកម្មវិធីសិក្សាផ្នែកខាងក្រៅ ឬនាយកនៅតាមសាលារៀនរបស់ពួកគេ ដើម្បីធ្វើការពិគ្រោះស្របតាមសេចក្តីត្រូវការ។

## ការដឹកជញ្ជូន

មន្ទីរអប់រំ ឡុងប៊ីច នឹងផ្តល់ការដឹកជញ្ជូនតាមរថយន្តក្រុងឈ្នួលទៅមកពី Hi Hill នៅ YMCA Camp Oakes ដោយគ្មានទាមទារថ្លៃឈ្នួលពីគ្រួសារ។ ***ប្រសិនបើមានមូលហេតុអ្វី ដែលតម្រូវឱ្យសិស្សត្រឡប់ទៅផ្ទះវិញក្នុងសប្តាហ៍ទៅចូលរួមកម្មវិធីសិក្សាផ្នែកខាងក្រៅ គឺមាតាបិតានឹងត្រូវទៅទទួលដកសិស្សមកផ្ទះវិញ ដោយចេញបង់ថ្លៃឈ្នួលខ្លួនឯង ។***

## កម្មវិធីសិក្សាផ្នែកខាងក្រៅ ដែលមានការទទួលស្គាល់ពេញច្បាប់

YMCA Camp Oakes មានការទទួលស្គាល់ពេញច្បាប់ក្នុងការប្រើប្រាស់ទីកន្លែង ដោយអង្គការ American Camp Association ដែលមានន័យថា វាជាទីកន្លែងធ្លាប់បានទទួលការត្រួតពិនិត្យដោយអ្នកជំនាញមកពីជាង 300 ក្រសួង ដើម្បីទាមទារឱ្យមានការរៀបចំ ស្របតាមស្តង់ដាផ្នែកសុខភាព និងសុវត្ថិភាព ដូចជា៖ ការគ្រប់គ្រងផ្នែកហានិភ័យ ការអប់រំកុមារ ទីកន្លែងហែលទឹក និងការមើលថែទាំសុខភាព។ ក្រសួងសុខាភិបាលប្រចាំ San Bernardino ខោនធី និងការិយាល័យផ្សេងៗរបស់ខោនធី/រដ្ឋ ក៏បានទៅធ្វើការត្រួតពិនិត្យដល់ទីកន្លែងផ្ទាល់ផងដែរសំរាប់កម្មវិធីសិក្សាផ្នែកខាងក្រៅនេះ ដែលស្របតាមតម្រូវការរបស់ច្បាប់។

## បន្ទប់ស្នាក់នៅ

គ្រូបង្រៀននឹងរៀបចំដាក់សិស្សជាក្រុមសំរាប់ការស្នាក់នៅតាមបន្ទប់ ដោយស្របទៅតាមភេទរបស់សិស្ស មុននឹងដល់ពេលចេញធ្វើដំណើរ។ គ្រូបង្រៀននឹងព្យាយាមអស់ពីសមត្ថភាព ដើម្បីរាប់បញ្ចូលយ៉ាងតិចមិត្តម្នាក់របស់សិស្សសំរាប់ស្នាក់នៅរួមគ្នា ប៉ុន្តែ មិនអាចធានាទេថា មិត្តទាំងអស់នឹងអាចស្នាក់នៅជុំគ្នាបាន។ បន្ទប់ស្នាក់នៅនឹងមានសិស្សមកពីបន្ទប់រៀនផ្សេងៗ ឬមកពីសាលារៀនផ្សេងៗក្នុងមន្ទីរអប់រំ LBUSD ដែលពួកគេនឹងទៅចូលរួមផងដែរក្នុងសប្តាហ៍ជាមួយគ្នា។

## ការត្រួតត្រាមើលនៅតាមបន្ទប់ស្នាក់នៅ

ក្រុមទាំងអស់នៅតាមបន្ទប់ស្នាក់នៅ នឹងមានការត្រួតត្រាមើលដោយមនុស្សធំជាអ្នកផ្តល់ឱវាទ ដែលមានចំនួនស្របតាមតម្រូវការរបស់អង្គការ American Camp Association។ បុគ្គលិកទាំងអស់ នឹងត្រូវបានទទួលការជ្រើសរើស ដោយយោងតាមសមត្ថភាពរបស់ពួកគេក្នុងការធ្វើកិច្ចការជាមួយកុមារ និងត្រូវចូលរួមក្នុងការហ្វឹកហ្វឺកជាច្រើនលើក មុននឹងដល់ពេលចេញធ្វើដំណើរទៅជាមួយសិស្ស។ បុគ្គលិកប្រចាំសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ គឺជាបុគ្គលិក ដែលមានការប្តេជ្ញាចិត្ត អមដោយបទពិសោធន៍ច្រើនឆ្នាំ ក្នុងការបំពេញកិច្ចការជាមួយសិស្ស។

LONG BEACH
UNIFIED SCHOOL DISTRICT
Excellence & Equity

the YMCA

Hi-Hill
at YMCA Camp Oakes
LBUSD

## **<u>ការរំលោភសិទ្ធិកុមារ</u>**

បុគ្គលិក YMCA Camp Oakes និងបុគ្គលិកប្រចាំមន្ទីរអប់រំ LBUSD ទាំងអស់ គឺជាអ្នកធ្វើរបាយការណ៍ ស្របតាមបទបញ្ញារបស់ច្បាប់។ បុគ្គលិកប្រចាំមន្ទីរអប់រំ LBUSD ទាំងអស់ត្រូវតែធ្វើរបាយការណ៍ស្របតាមបទបញ្ញារបស់ច្បាប់អំពីការរំលោភសិទ្ធិកុមារ (ដូចជា៖ ការវាយធ្វើបាប ការបំបាក់ទឹកចិត្ត ការជេរស្តី និង/ឬការមើលថៃដោយមិនយកចិត្តទុកដាក់ ជាដើម) ទៅកាន់អាជ្ញាធរត្រឹមត្រូវភ្លាមៗ។

## **<u>ជំងឺនឹកផ្ទះ</u>**

ការនៅដាច់ឆ្ងាយពីផ្ទះអស់ពេលមួយសប្តាហ៍ អាចក្លាយជាបទពិសោធន៍លំបាកម្យ៉ាងសំរាប់កុមារគ្រប់អាយុទាំងអស់។ នៅពេលកុមារស្ថិតនៅឆ្ងាយពីផ្ទះជាលើកដំបូង ពួកគេប្រហែលជានឹកផ្ទះ។ មុននឹងដល់ពេលចេញដំណើរ យើងស្នើសុំឱ្យលោកអ្នកនិយាយប្រាប់កូនរបស់លោកអ្នកថា លោកអ្នកមានការទុកចិត្តលើពួកគេក្នុងការអាចដោះស្រាយបានអំពីបទពិសោធន៍ថ្មី។ សូមធ្វើការសង្កត់លើតែអ្វី ដែលជាចំណុចល្អ មិត្តភាពថ្មី និងសកម្មភាពផ្សេងៗ ដែលពួកគេនឹងចូលរួមសប្បាយ និងការសរសើរពីលោកអ្នកចំពោះភាពជោគជ័យរបស់ពួកគេ។ នៅពេលធ្វើដំណើរទៅដល់ទីកន្លែងហើយ បុគ្គលិកនឹងប្រើមធ្យោបាយដ៏ពិសេសៗ ដើម្បីបំបាត់ចោលនូវជំងឺនឹកផ្ទះ – ដោយធ្វើឱ្យសិស្សនៅតែជាប់រវល់ និងទទួលបាននូវភាពសប្បាយជានិច្ច។ យើងខ្ញុំស្នើសុំឱ្យមាតាបិតាសរសេរសំបុត្រផ្ញើពីផ្ទះ ដើម្បីឱ្យសិស្សអាន និងស្តាប់ឮអំពីការលើកទឹកចិត្តទៅកាន់ពួកគេ។ សូមចងចាំថា Camp Oakes បានផ្តល់ជាបទពិសោធន៍ដ៏ល្អមកកាន់សិស្សរាប់ពាន់នាក់ក្នុងរយៈពេលឆ្នាំកន្លងមក ហើយយើងខ្ញុំដឹងថា កូនរបស់លោកអ្នកក៏បានទទួលនូវបទពិសោធន៍ដ៏ល្អដូច្នោះដែរ។

## **<u>ការត្រៀមទុក មុននឹងដល់ពេលចេញធ្វើដំណើរ</u>**

សាលាកម្មវិធីសិក្សាផ្នែកខាងក្រៅផ្តល់ឱកាសសំរាប់សិស្សរបស់លោកអ្នកកសាងនូវជំរៅទឹកចិត្តរបស់ពួកគេ ដែលនឹងបង្កើនជាជំនាញបន្ថែមផ្នែកធ្វើទំនាក់ទំនង។ ពួកគេនឹងបង្កើននូវសមត្ថភាពផ្នែកឯករាជ្យភាព និងទំនួលខុសត្រូវ ដោយចេះថៃទាំខ្លួនឯង រៀបចំគ្រែគេង និងរក្សាទុកនូវរបស់ប្រើប្រាស់ផ្ទាល់ខ្លួន។ នៅផ្ទះ គឺយើងស្នើសុំឱ្យមាតាបិតាជួយសិស្សរៀបចំរបស់សំរាប់ដាក់ទៅជាមួយ ដោយប្រើ<u>**បញ្ជីត្រួតពិនិត្យ មុននឹងដល់ពេលចេញធ្វើដំណើរសំរាប់សិស្ស**</u>។ ការធ្វើដូច្នេះ គឺជួយសិស្សមានទំនួលខុសត្រូវកាន់តែច្រើន ក្នុងពេលដែលពួកគេត្រៀមទុកសំរាប់ការទទួលបាននូវបទពិសោធន៍មួយដ៏រំភើបនេះ។ សិស្សមិនអាចរៀបដាក់កញ្ចប់ចំណី និង/ឬគ្រាប់ស្ករទៅជាមួយបានទេ។ សូមធ្វើការយកចិត្តទុកដាក់ ដើម្បី**កុំ**ឱ្យលោកអ្នក និងកូនរបស់លោកអ្នករៀបដាក់របស់ដូចតទៅនេះទៅ Camp Oakes ឱ្យសោះ៖

**<u>របស់មិនអាចយកទៅបាន - កុំយកទៅជាមួយ!</u>**

- គ្រឿង អេឡិចត្រូនិច **<u>គ្រប់ប្រភេទ</u>** ដូចជា៖
  - ទូរស័ព្ទដៃ ឬ ឧបករណ៍ធ្វើទំនាក់ទំនងផ្សេងៗ
  - ឡេបថប, ថេប្លិត, iPod, ឧបករណ៍ពាក់ភ្ជាប់ត្រចៀក ឬ នាឡិកា Smart Watch
  - ឧបករណ៍ ហ្គេម សំរាប់កាន់លេង
- ដែកកេះ ឬ កាំជ្រួច
- កាំបិត ឬ កូនពូថៅដៃ
- កាំភ្លើង
- គ្រឿងថ្នាំជក់
- គ្រឿងថ្នាំខុសច្បាប់
- ចំណី
- ស្ករទំពារ ឬ គ្រាប់ស្ករ
- ថ្នាំបាញ់សំអាតក្លិន

ចំពោះរបស់ប្រើប្រាស់ទាំងឡាយណា ដែលគ្មានការអនុញ្ញាតឱ្យយកទៅជាមួយ គឺនឹងត្រូវដកហូតទុក ដោយមានការសរសេរឈ្មោះសិស្សរបស់លោកអ្នកនៅពីលើ និងរក្សាទុកដោយបុគ្គលិក ទំរាំតែដល់ថ្ងៃចេញដំណើរត្រឡប់ទៅផ្ទះវិញ។ របស់ ដែលត្រូវបានដកហូតទុក គឺនឹងប្រគល់ជូនបុគ្គលិកសាលារៀន ឬមាតាបិតាវិញ ស្របតាមកាលៈទេសៈត្រឹមត្រូវ បន្ទាប់ពីបានធ្វើដំណើរត្រឡប់ទៅផ្ទះវិញ។ មន្ទីរអប់រំ LBUSD និង/ឬ អង្គការ YMCA គ្មានទំនួលខុសត្រូវទេលើរបស់ប្រើប្រាស់ ដែលត្រូវបានបាត់បង់ ឬបាក់បែកក្នុងពេលធ្វើដំណើរការនេះ។

LONG BEACH UNIFIED SCHOOL DISTRICT Excellence & Equity

the YMCA

# គោលការណ៍ច្បាប់ និង នីតិវិធីរបស់ Hi Hill នៅ YMCA Camp Oakes

## <u>ការប្រើថ្នាំពេទ្យ</u>

សូមកុំដាក់ថ្នាំពេទ្យឱ្យសោះនៅក្នុងវ៉ាលីសនៃសិស្សរបស់លោកអ្នក ដែលរាប់បញ្ចូលផងទាំងថ្នាំពេទ្យទិញ ដោយមិនបាច់មានវេជ្ជបញ្ជា។ **ថ្នាំពេទ្យទាំងអស់ (ទាំងថ្នាំពេទ្យតាមវេជ្ជបញ្ជា និងគ្មានវេជ្ជបញ្ជា) រួមទាំងឯកសារតម្រូវចាំបាច់ផ្សេងៗ គឺត្រូវតែដាក់ផ្ញើបញ្ជូនទៅកាន់គិលានុប្បដ្ឋាយិកាសាលារៀន យ៉ាងហោចណាស់មួយសប្តាហ៍ មុននឹងដល់ពេលចេញធ្វើដំណើរ។** គិលានុប្បដ្ឋាយិកានឹងពិនិត្យមើលថ្នាំពេទ្យទាំងអស់ និងកត់ទុកក្នុងបញ្ជី អនឡាញ។ ប្រសិនបើសិស្សរបស់លោកអ្នកត្រូវការប្រើថ្នាំពេទ្យនៅឯសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ គឺថ្នាំពេទ្យមួយមុខៗ ត្រូវមានការសរសេរបង្ហាញលើក្រដាស "Medication at Camp" ដែលត្រូវតែបំពេញឡើងដោយវេជ្ជបណ្ឌិតរបស់សិស្ស។ នេះរាប់បញ្ចូលផងទាំងថ្នាំពេទ្យទិញ ដោយគ្មានវេជ្ជបញ្ជា។ ថ្នាំពេទ្យតាមវេជ្ជបណ្ឌិត គឺត្រូវតែមាននៅក្នុងដប ដែលបង្ហាញឈ្មោះឱសថស្ថាន និងមានឈ្មោះនៃសិស្សរបស់លោកអ្នកសរសេរបង្ហាញនៅពីលើ រួមទាំងមានការសរសេរបង្ហាញច្បាស់លាស់ទៀតផងពីវេជ្ជបណ្ឌិតអំពីរបៀបត្រូវប្រើ។ ចំពោះថ្នាំពេទ្យទាំងអស់ ដែលគ្មានវេជ្ជបញ្ជា គឺត្រូវមាននៅក្នុងដបជាប្រភពដើម ដោយមានឈ្មោះនៃសិស្សរបស់លោកអ្នកសរសេរបង្ហាញជាមួយផង។ <u>ថ្នាំផ្សេងៗ (រាប់ទាំងថ្នាំបំប៉ន វីតាមីន ផង) គឺមិនអាចទុកប្រើក្នុងបន្ទប់ស្នាក់នៅបានទេ</u> - គិលានុប្បដ្ឋាយិកា Hi Hill នៅ YMCA Camp Oakes នឹងដាក់ថ្នាំពេទ្យទាំងអស់ឱ្យសិស្សប្រើ។ សូមផ្តល់ថ្នាំពេទ្យ ដែលអាចប្រើបានដល់ទៅចំនួនពេល 10 ថ្ងៃ ដើម្បីឱ្យយើងខ្ញុំត្រៀមទុកអំពីស្ថានភាពណាមួយ ដែលអាចកើតមានឡើង (ដូចជា៖ អាកាសធាតុមិនល្អ ជាដើម)។ សូមទាក់ទងជួបគិលានុប្បដ្ឋាយិកាសាលារៀន ដើម្បីស្នើសុំក្រដាសបំពេញការប្រើថ្នាំពេទ្យ (Medication at Camp form) និងសួរជាសំណួរផ្សេងៗ។

## <u>ការប្រើទូរស័ព្ទដៃ/ការធ្វើទំនាក់ទំនងផ្សេងៗជាមួយសិស្ស</u>

ទូរស័ព្ទដៃ ថេប្លិត និងនាឡិកា smart watch គឺត្រូវទុកនៅឯផ្ទះ។ ហាមមិនឱ្យសិស្សយករបស់ទាំងអស់នោះទៅជាមួយ។ ក្រុមគ្រួសារត្រូវបានទទួលការលើកទឹកចិត្ត ឱ្យសរសេរជាសំបុត្រផ្ញើជូនសិស្សរបស់ពួកគេរៀងៗខ្លួន ស្របតាមអ្វី ដែលបានលើកបង្ហាញពីទំព័រមុនមក។

## <u>មធ្យោបាយធ្វើទំនាក់ទំនងជាមួយកូនរបស់លោកអ្នក</u>

ក្រុមគ្រួសារទទួលការស្វាគមន៍ចំពោះការផ្ញើសំបុត្រទៅកាន់សិស្ស នៅពេលពួកគេកំពុងស្នាក់នៅសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ។ សូមសរសេរសំបុត្រមួយ ឬពីរ ដោយមានពាក្យរៀបរាប់ពិរោះស្តាប់ និងផ្តល់ជូនគ្រូបង្រៀននៃសិស្សរបស់លោកអ្នក មុននឹងដល់ពេលត្រូវចេញធ្វើដំណើរ។ សិស្សនឹងបានទទួលសំបុត្រទាំងអស់នេះនៅពេលពាក់កណ្តាលសប្តាហ៍។ សិស្សនឹងមានការសប្បាយចិត្ត នៅពេលបានទទួលសំបុត្រ ប៉ុន្តែ សូមសរសេរជាពាក្យពិរោះស្តាប់ និងបង្ហាញការលើកទឹកចិត្ត។

## <u>ការមើលថែសុខភាព</u>

គ្មានសិស្សម្នាក់ណា ដែលមានជំងឺ អាចចូលរួមនៅសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅបានឡើយ។ ប្រសិនបើសិស្សមានជំងឺ គឺ Camp Oakes មានគិលានុប្បដ្ឋាយិកាធ្វើការប្រចាំកន្លែង។ ប្រសិនបើសិស្សមានជំងឺមែន គឺសិស្សនឹងស្នាក់នៅក្នុងបន្ទប់សុខភាពដាច់តែឯងមួយតាមរយៈពេលត្រឹមត្រូវ។ ប្រសិនបើចាំបាច់ គឺយើងខ្ញុំនឹងទាក់ទងមាតាបិតា/អាណាព្យាបាល ដើម្បីស្នើសុំឱ្យទៅទទួលយកសិស្សរបស់ពួកគាត់។ ប្រសិនបើសិស្សមានជំងឺ មុននឹងដល់ពេលត្រូវចេញធ្វើដំណើរ គឺគិលានុប្បដ្ឋាយិកាសាលារៀននឹងធ្វើការពិនិត្យច្បាស់លាស់ ដើម្បីបញ្ជាក់ថា សិស្សពិតជាមានសុខភាពមាំទាំមែន ដើម្បីធ្វើដំណើរទៅកាន់ភ្នំបាន ដែលពោរពេញដោយសកម្មភាពបញ្ចេញកំឡាំងច្រើន។

សិស្សទាំងឡាយណា ដែលមានលក្ខណៈសុខភាពមិនល្អ ដូចជា៖ គ្រុនកំដៅ 100.4 អង្សា ឬកាន់តែខ្ពស់ ឈឺបំពង់ក ក្អួត រាគ រមាស់ស្បែកមិនឈប់ របួសរបកស្បែក ឬដំបៅ និង/ឬមានចៃក្បាល (ពងចៃ ឬចៃរស់រវើក) គឺនឹងមិនអាចចូលរួមបានឡើយ ដើម្បីការពារសុខភាពរបស់មនុស្សដទៃ។

ប្រសិនបើមានគ្រាអាសន្ន ឬគ្រា ដែលតម្រូវសេចក្តីត្រូវការពិសេសអ្វីមួយ គឺសេវាព្យាបាលក្នុងភាពអាសន្ននឹងមានផ្តល់នៅទីក្រុង Big Bear Lake។ ប្រសិនបើមានការរងរបួស គឺយើងខ្ញុំនឹងប្រើមធ្យាបាយចាំបាច់គ្រប់យ៉ាង ដោយធ្វើការយកចិត្តទុកដាក់ត្រឹមត្រូវ ដែលមានដូចជា៖ ការធ្វើការព្យាបាលដោយបុគ្គលិកផ្ទាល់លើមុខរបួសស្រាលៗ ការទាក់ទងមាតាបិតា/អាណាព្យាបាល ដើម្បីស្នើសុំយោបល់ ការទាក់ទងហៅមន្ទីរព្យាបាលនៅក្បែរៗ ឬការដឹកជញ្ជូនសិស្សទៅមន្ទីរពេទ្យ។ យើងខ្ញុំនឹងធ្វើការទាក់ទងមាតាបិតា ប្រសិនបើសិស្សមានកំដៅខ្លួន 100.4 អង្សា ឬកាន់តែខ្ពស់ ហើយសិស្សប្រហែលជាមិនអាចចូលរួមបន្តបានទៀតទេក្នុងសកម្មភាពនៅសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ។

Hi-Hill at YMCA Camp Oakes LBUSD

សំខាន់ណាស់ ដែលលោកអ្នកត្រូវផ្តល់ព័ត៌មានទាក់ទងច្បាស់លាស់សំរាប់គ្រាអាសន្ន នៅក្នុងដំណើរការចុះឈ្មោះចូលរួម។ ប្រសិនបើលោកអ្នកនឹងធ្វើដំណើរឆ្ងាយពីផ្ទះ គឺសូមមេត្តារាយបង្ហាញឈ្មោះនៃទីកន្លែង ដែលត្រូវទៅ និងលេខទូរស័ព្ទងាយទាក់ទងលោកអ្នក។ ប្រសិនបើសិស្សមានរបួស ដែលតម្រូវការព្យាបាល គឺបុគ្គលិក YMCA Camp Oakes និង/ឬបុគ្គលិកប្រចាំមន្ទីរអប់រំ LBUSD នឹងព្យាយាមធ្វើការទាក់ទងលោកអ្នក ប៉ុន្តែ ប្រសិនបើធ្វើការទាក់ទងមិនជួប គឺយើងខ្ញុំនឹងផ្តល់សិទ្ធិជូនវេជ្ជបណ្ឌិតដែលត្រូវបានជ្រើសរើសដោយបុគ្គលិក YMCA Camp Oakes និង/ឬបុគ្គលិកប្រចាំមន្ទីរអប់រំ LBUSD ឱ្យធ្វើការព្យាបាល ស្របតាមអ្វីដែលជាការចាំបាច់ និងត្រឹមត្រូវដោយវេជ្ជបណ្ឌិត។

**<u>ការធានារ៉ាប់រងផ្នែកសុខភាព</u>**

ក្នុងនាមជាមាតាបិតា ឬអាណាព្យាបាល គឺលោកអ្នកទទួលខុសត្រូវលើថ្លៃព្យាបាល ដែលកើតឡើងដោយសារការរងរបួស ឬជំងឺ នៅពេលសិស្សរបស់លោកអ្នកចូលរួមក្នុងការធ្វើដំណើរ។ ចំពោះក្រុមគ្រួសារ ដែលគ្មានការធានារ៉ាប់រងផ្នែកសុខភាព គឺយើងខ្ញុំស្នើសុំឱ្យបើកចូលពិនិត្យនៅ www.CoveredCA.com ហើយចំពោះក្រុមគ្រួសារផ្សេងទៀត ដែលចង់ធ្វើការជ្រើសរើសយកការធានារ៉ាប់រងផ្នែកគ្រោះថ្នាក់សំរាប់សិស្ស ដោយចេញបង់ផ្ទាល់ខ្លួនឯង គឺគួរអានបន្ថែមអំពីគោលការណ៍ច្បាប់របស់មន្ទីរអប់រំ LBUSD សំរាប់មាតាបិតា និងសិស្ស។ សូមទទួលស្គាល់ថា មន្ទីរអប់រំគ្មានការធានារ៉ាប់រងអ្វីលើថ្លៃព្យាបាល ឬថ្លៃបង់មន្ទីរពេទ្យនោះទេ និងម្លោះហើយ ថ្លៃអ្វីទាំងអស់ ដែលបានកើតឡើងសំរាប់ការព្យាបាល គឺជាមុខងារទទួលខុសត្រូវតែមួយគត់របស់មាតាបិតា/អាណាព្យាបាល។ សូមធ្វើការបញ្ជាក់ ដោយផ្តល់ជាព័ត៌មានច្បាស់លាស់អំពីការធានារ៉ាប់រងផ្នែកសុខភាពរបស់លោកអ្នកនៅក្នុងប្រព័ន្ធចុះឈ្មោះ។

**<u>ការបាត់បង់ និងរបស់ប្រើប្រាស់ដែលត្រូវបានរកឃើញមកវិញ</u>**

Camp Oakes គឺជាកន្លែងផ្តល់បទពិសោធន៍មួយសំរាប់សិស្សរៀនទទួលខុសត្រូវចំពោះរបស់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ។ សូមពិគ្រោះជាមួយសិស្សរបស់លោកអ្នកអំពីការចេះទទួលខុសត្រូវ និងការថែរក្សានូវរបស់ប្រើប្រាស់របស់ពួកគេ។ មន្ទីរអប់រំ LBUSD និង YMCA គ្មានការទទួលខុសត្រូវទេចំពោះរបស់ប្រើប្រាស់ ដែលត្រូវបានបាត់បង់ ឬត្រូវបានមនុស្សផ្សេងលួចលាក់ទុក។ **<u>សូមកុំរៀបដាក់ផ្ញើរបស់មានតម្លៃ</u>**ទៅជាមួយសិស្សរបស់លោកអ្នកឱ្យសោះ។

របស់ប្រើប្រាស់ទាំងឡាយណា ដែលត្រូវបានបាត់បង់ និងត្រូវបានរកឃើញដោយបុគ្គលិក គឺនឹងដាក់តាំងនៅទូទាំងមួយសប្តាហ៍ ដើម្បីឱ្យសិស្សមកប្រមូលយកវិញ។ របស់ប្រើប្រាស់ទាំងឡាយណា ដែលបានភ្លេចចោល ឬត្រូវបានរកឃើញ បន្ទាប់ពីសិស្សបានចេញត្រឡប់ទៅផ្ទះវិញ គឺនឹងរក្សាទុកក្នុងសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ មិនលើសពីចំនួនពេល 2 សប្តាហ៍។ យើងខ្ញុំនឹងព្យាយាមស្របតាមហេតុផល ដើម្បីបញ្ជូនរបស់ ដែលត្រូវបានបាត់បង់ និងបានរកឃើញ ទៅកាន់ម្ចាស់ដើមវិញ ប៉ុន្តែ ប្រសិនបើគ្មានម្ចាស់ដើមមកទាមទារយកវិញនោះទេក្នុងរយៈពេល 2 សប្តាហ៍ គឺយើងខ្ញុំនឹងប្រហែលជាយកទៅប្រគល់ជូនអង្គការមិនយកកម្រៃប្រចាំមូលដ្ឋាន។ **សូមសរសេរឈ្មោះនៃសិស្សរបស់លោកអ្នកនៅលើរបស់ប្រើប្រាស់ទាំងអស់របស់ពួកគេ។**

**<u>វិន័យ/ការរំពឹងទុកលើអាកប្បកិរិយា</u>**

សិស្សនឹងត្រូវតែគោរពតាមវិន័យទាំងអស់របស់មន្ទីរអប់រំ LBUSD របស់សាលារៀននីមួយៗ និងការរំពឹកទុករបស់ YMCA Camp Oakes ផ្នែកអាកប្បកិរិយា និងសុវត្ថិភាព ដែលស្របតាមច្បាប់អប់រំលេខ Ed. Code 48900។ ដើម្បីរក្សានូវសុវត្ថិភាព និងភាពសន្តិសុខបានកាន់តែខ្ពស់ គឺសិស្សនឹងចូលរួមពិគ្រោះ និងរៀបចំបង្កើតជាវិន័យសំរាប់ប្រើក្នុងបន្ទប់ស្នាក់នៅ។ គ្រូបង្រៀនប្រចាំមន្ទីរអប់រំ LBUSD និងបុគ្គលិក YMCA Camp Oakes នឹងបង្ហាញជាគំរូល្អអំពីអាកប្បកិរិយា ដោយរៀបចំជាមធ្យោបាយត្រឹមត្រូវសំរាប់ប្រើជាមួយ។
វិន័យប្រើជាមួយនៅតាមសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅនឹងចែករំលែកទៅកាន់សិស្ស នៅពេលសិស្សធ្វើដំណើរទៅដល់ទីកន្លែង។ វិន័យដ៏សំខាន់ជាងគេ គឺ៖

1) **រក្សានូវសុវត្ថិភាពគ្រប់ពេលវេលា 2) បង្ហាញនូវសេចក្តីគោរព** និង **3) ទទួលនូវការសប្បាយ!** គោលការណ៍ណែនាំរបស់សាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ គាំទ្រលើវិន័យទាំងអស់នេះ ដែលមានដូចជា៖ នៅជាមួយមនុស្សធំ និងមិត្តជាក្រុមរបស់អ្នកគ្រប់ពេលវេលា និងបង្ហាញនូវសេចក្តីគោរពទៅកាន់មនុស្សផ្សេងៗ និងរាល់ទីកន្លែង គ្រប់ពេលវេលា។

ការបង្ហាញនូវអំពើមិនសមរម្យ ដែលគ្មានភាពត្រឹមត្រូវដូចតាមការរំពឹងទុក គឺនឹងធ្វើការដោះស្រាយឡើងវិញតាមមធ្យោបាយត្រជាក់ និងធ្វើការណែនាំក្នុងការស្វែងរកដំណោះ

ស្រាយ ដែលស្របដោយសេចក្តីគោរពដាក់គ្នា ការធ្វើទំនាក់ទំនង ដែលស្របដោយប្រសិទ្ធិភាព និងមិត្តភាពស្និទ្ធស្នាល។ ការប្រើមធ្យោបាយទាំងអស់នេះ ត្រូវបានរៀបចំឡើង ដើម្បីកសាងជំរៅទឹកចិត្តរបស់សិស្ស ពង្រឹងជំនាញផ្នែកទឹកចិត្តរាប់អានគ្នា និងដើម្បីធ្វើការបញ្ជាក់ថា សិស្សទាំងអស់នឹងទទួលបាននូវបទពិសោធន៍ល្អមែន ដែលស្របដោយសុវត្ថិភាព និងការគាំទ្រ។

តទៅនេះ គឺជាមធ្យោបាយ ដើម្បីធ្វើការដោះស្រាយជាមួយសិស្សទាំងឡាយណា ដែលបង្ហាញនូវអាកប្បកិរិយាមិនសមរម្យ៖

***ជួបជាមួយសិស្ស*** *- អ្នកមើលខុសត្រូវសិស្សតាមបន្ទប់ស្នាក់នៅ ឬបុគ្គលិកផ្សេងៗនឹងពិគ្រោះអំពីវិន័យ មូលហេតុអំពីការប្រើវិន័យ និងជួយសិស្សឱ្យគិតមើលឡើងវិញអំពីឥទ្ធិពល ដែលប៉ះពាល់លើសកម្មភាពរបស់ពួកគេ។*

***ការគិតមើលឡើងវិញ និងការកែតម្រូវឡើងវិញ*** *- អ្នកមើលខុសត្រូវសិស្សតាមបន្ទប់ស្នាក់នៅ ឬបុគ្គលិកផ្សេងៗនឹងពិគ្រោះអំពីអាកប្បកិរិយាមិនសមរម្យ លើកទឹកចិត្តសិស្សឱ្យគិតមើលឡើងវិញចំពោះសកម្មភាពរបស់ពួកគេ និងណែនាំសិស្សឱ្យបែរមករកការកាន់ភ្ជាប់នូវអាកប្បកិរិយាល្អឡើងវិញ។ មនុស្សធំនឹងជួយគាំទ្រសិស្សឱ្យធ្វើការយកចិត្តទុកដាក់លើអាកប្បកិរិយាត្រឹមត្រូវ ជំនួសអាកប្បកិរិយាមិនសមរម្យ។ គ្រូបង្រៀនរបស់សិស្សនឹងបានទទួលដំណឹងអំពីមូលហេតុ ដែលបានកើតឡើង និងស្នើសុំឱ្យជួយបង្ហាញជាមធ្យោបាយដោះស្រាយ។ គ្រូបង្រៀនរបស់សិស្សប្រហែលជាចូលរួម និង/ឬ ជួយដោះស្រាយក្នុងការពិគ្រោះទាំងអស់នេះ។*

***ការបន្ធូរភាពតានតឹង និងការកែសម្រួល*** *- បុគ្គលិកនឹងទុកពេលឱ្យសិស្សគិតមើលឡើងវិញអំពីអាកប្បកិរិយារបស់ពួកគេ ឬគ្រាន់តែទុកពេលឱ្យមាន "ការត្រជាក់ចិត្ត" មួយសន្ទុះសិន ទំរាំតែស្ថានការមានភាពធូរស្បើយ ដែលអាចពិគ្រោះជាមួយសិស្សបាន។ បុគ្គលិកនឹងជួយសិស្សឱ្យចេះធ្វើការសុំទោស និងធ្វើឱ្យមានការប្រែទៅដូចស្ថានការដើមឡើងវិញ ប្រសិនបើអាចធ្វើបាន។ យើងខ្ញុំនឹងធ្វើការទាក់ទងមាតាបិតា ហើយពួកគេនឹងបានទទួលដំណឹងអំពីហេតុការណ៍។*

***ការប្រជុំជាមួយមាតាបិតា*** *- បុគ្គលិកនឹងប្រើមធ្យោបាយគ្រប់យ៉ាង ដើម្បីធ្វើការដោះស្រាយបញ្ហាផ្នែកអាកប្បកិរិយារបស់សិស្សនៅសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ។ មាតាបិតានៃសិស្ស ដែលបង្ហាញការខ្វះខាតផ្នែកការឆ្លើយតប ឬទំនួលខុសត្រូវ គឺប្រហែលជានឹងបានទទួលការទាក់ទងតាមរយៈទូរស័ព្ទដោយបុគ្គលិក ដើម្បីធ្វើការដោះស្រាយបញ្ហាផ្នែកអាកប្បកិរិយា។ មាតាបិតានឹងបានទទួលដំណឹងតាមការជួបពិគ្រោះតាមរយៈទូរស័ព្ទជាមួយបុគ្គលិកប្រចាំសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ និងបុគ្គលិកប្រចាំសាលារៀន ដើម្បីធ្វើការដោះស្រាយបញ្ហាអាកប្បកិរិយា។ បន្ថែម ការបង្ហាញនូវអាកប្បកិរិយាមិនសមរម្យ គឺអាចបណ្តាលឱ្យសិស្សទទួលបាននូវការបណ្តេញចេញពីសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ។*

***ទំនួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន*** *- ចំពោះសិស្ស ដែលមិនអាចគោរពតាមវិន័យបាន ឬធ្វើបណ្តាលឱ្យមានការប៉ះពាល់ដល់បទពិសោធន៍អវិជ្ជមានទៅកាន់សិស្សដទៃ គឺប្រហែលជានឹងបាត់បង់សិទ្ធិ ឬការប្រើប្រាស់ឧបករណ៍ជាក់លាក់មួយរយៈពេលខ្លី។ ប្រសិនបើសិស្សនៅតែធ្វើបន្ត ដោយមិនគោរពតាមវិន័យ និងការរំពឹកទុកផ្សេងៗ គឺពួកគេនឹងប្រហែលជាបាត់បង់សិទ្ធិក្នុងការចូលរួមជាបន្ថែម និងទទួលការបញ្ជូនឱ្យត្រឡប់ទៅផ្ទះវិញ។* ***មាតាបិតានឹងទទួលខុសត្រូវក្នុងការធ្វើដំណើរទៅយកសិស្សរបស់ខ្លួនត្រឡប់ទៅផ្ទះវិញពីសាលាកម្មវិធីសិក្សាផ្នែកខាងក្រៅ។***

Hi-Hill at YMCA Camp Oakes LBUSD

# បញ្ជីត្រួតពិនិត្យ មុននឹងចេញធ្វើដំណើរ

**ការរៀបចំទុកជាមុន៖**

________ បំពេញព័ត៌មានទាំងអស់តាមការចុះឈ្មោះ អនឡាញ មុននឹងដល់ថ្ងៃខែកំណត់។

________ ផ្ញើមកវិញនូវក្រដាសស្នាម ដែលត្រូវបានបំពេញ និងចុះហត្ថលេខាសំរាប់ការអនុញ្ញាតឱ្យសិស្សធ្វើដំណើរជាមួយមន្ទីរអប់រំ LBUSD។

________ តាមដានមើលសុខភាពរបស់សិស្សរាល់ថ្ងៃ មុននឹងដល់ពេលចេញធ្វើដំណើរ។ សិស្សអាចទទួលការដកឈ្មោះពីការចូលរួមធ្វើដំណើរបាន ប្រសិនបើគេមានបញ្ហាសុខភាពជាក់លាក់ណាមួយ ដូចជា៖ កន្ទួលស្បែក ដែលមិនទាន់បានធ្វើរោគវិនិច្ឆ័យ មានចៃក្បាល/ពងចៃក្បាល ឬជំងឺឆ្លងផ្សេងៗ ដែលមានការសង្ស័យចំពោះ។

________ **ថ្នាំពេទ្យ គឺត្រូវប្រគល់ជូនគិលានុប្បដ្ឋាយិកាសាលារៀន ដោយមានមកជាមួយ**នូវឯកសារចាំបាច់ទាំងអស់ មិនឱ្យលើសពីពេលមួយសប្តាហ៍ មុននឹងដល់ពេលចេញធ្វើដំណើរ។

**ថ្ងៃចេញធ្វើដំណើរ៖**

________ នាំយក វ៉ាលីស ប្រដាប់គេង និងរបស់ប្រើប្រាស់ផ្សេងៗទៀតរបស់អ្នកមកជាមួយ ដោយមានឈ្មោះរបស់អ្នកសរសេរនៅពីលើយ៉ាងច្បាស់។

________ សិស្សទាំងអស់នឹងទទួលនូវការពិនិត្យមើលជំងឺឆ្លង ដែលអាចមាន (ដូចជា៖ គ្រុនក្តៅ ឈឺបំពង់ក កន្ទួលស្បែក ចៃក្បាល/ពងចៃ)។

________ **ថ្នាំពេទ្យប្រហែលជាមិនអាចដាក់ភ្ជាប់ខ្លួនតាមសិស្សបានទេ។** ថ្នាំពេទ្យទាំងអស់ គឺត្រូវប្រគល់ជូនគិលានុប្បដ្ឋាយិកាសាលារៀន មិនតិចពេលជាងមួយសប្តាហ៍ មុននឹងដល់ពេលចេញធ្វើដំណើរ។

________ **ស្លៀកខោជើងវែង** និងពាក់ស្បែកជើងសមលក្ខណៈងាយដើរ/ដើរឡើងទួល។

LONG BEACH UNIFIED SCHOOL DISTRICT Excellence & Equity

the YMCA

# បញ្ជីឈ្មោះរបស់ដែលត្រូវរៀបដាក់ទៅជាមួយ

***បញ្ជាក់មើលថា ឈ្មោះរបស់អ្នក និងឈ្មោះសាលារៀន គឺពិតជាមានសរសេរច្បាស់លាស់មែននៅតាម វ៉ាលីស ទាំងអស់។***

សិស្សអាចរៀបដាក់បានដល់ទៅ បី វ៉ាលីស។ ***សិស្សគួរតែអាចកាន់ ឬយួរវ៉ាលីសទាំងអស់ បី នោះបានពីរថយន្តក្រុងធំ ទៅកាន់បន្ទប់ស្នាក់នៅរបស់គេក្នុងដំណើរតែមួយជើង***

**វ៉ាលីស #1៖ កាតាបស្ពាយសាលារៀន** - កាន់ភ្ជាប់ខ្លួននៅពេលជិះរថយន្តក្រុងធំ

កាតាបស្ពាយនេះត្រូវនៅជាមួយអ្នកគ្រប់ពេលវេលា។

-ដបទឹក ដែលមានឈ្មោះរបស់អ្នក
-ស្រោមដៃ
-អាវរងា
-អាវយឺតក្រាស់ដៃវែង
-កូនពិល
-ស្រោមជើងបន្ថែម
-អាវក្រាស់ធំ/អាវភ្លៀង (ការពារខ្យល់/មិនសើមទទឹក)
-មួកពាក់ងំក្បាល

**វ៉ាលីស #2៖ វ៉ាលីស (ដែលកាន់បាន)** - អាចយកប្រើប្រាស់បាន បន្ទាប់ពីពេលអាហារល្ងាច

ស្នើសុំឱ្យរៀបដាក់គ្រឿងសំអិតសំអាតខ្លួននៅក្នុងថង់ Ziploc ធំ។

**វ៉ាលីស #3៖ ថង់គេង ឬកន្ទេល** - អាចយកប្រើប្រាស់បាន បន្ទាប់ពីពេលអាហារល្ងាច

មានខ្នើយមួយ និងថង់គេងមួយ ដែលបានរៀបដាក់ក្នុងថង់សំរាមធំមួយ (សំរាប់ការពារអាកាសធាតុ)។ សរសេរឈ្មោះរបស់អ្នក និងឈ្មោះសាលារៀនលើថង់។ កំរាល និងភួយធំ គឺអាចប្រើបានសំរាប់ធ្វើជាកន្ទេល។

**របស់ប្រើប្រាស់ចាំបាច់៖**

______ ប្រេងលាបបបូរមាត់
______ ស្បែកជើង (2 គូ) ត្រូវគ្របបិទម្រាមជើងឱ្យជិត
______ ខោវែង (3 គូ) (មិនមែនខោខ្លី)
______ អាវធំក្រាស់
______ មួកយឺតរុំក្បាល
______ ស្រោមជើង (មានជាតិកប្បាស ឬជាតិរោមចៀម) (6-8 គូ)
______ ថ្នាំដុសធ្មេញ និងច្រាសដុសធ្មេញ
______ ច្រាសសិតសក់ ឬស្និតសក់
______ អាវយឺតដៃខ្លី (5)
______ ស្រោមដៃក្រាស់
______ ប្រេងការពារស្បែកក្រោមកំដៅថ្ងៃ (មិនមែនបាញ់សាច)
______ ស្បែកជើងពាក់ងូតទឹក
______ អាវយឺតក្រាស់ (2)
______ ខោអាវស្លៀកគេង
______ អាវដៃវែង (2)
______ ខោទ្រនាប់ (8 គូ)
______ មួកមានគែម
______ សាប៊ូ និងសាប៊ូកក់សក់
______ ថ្នាំបំបាត់ការធុំក្លិនក្លៀក (មិនមែនបាញ់សាច)
______ កន្សែងជូតខ្លួន និងកន្សែងតូចជូតមុខ

**របស់ប្រើប្រាស់ផ្សេងៗ ដែលអាចជ្រើសរើសរៀបដាក់មកជាមួយបាន៖**

_______ ថង់សំរាប់ដាក់ទុកដាក់សំលៀកបំពាក់ បន្ទាប់ពីបានប្រើរួចមក
_______ កាមេរ៉ាថតរូប (ចង់បាន តែប្រើហើយ បោះចោល)
_______ វ៉ែនតាខ្មៅការពារកំដៅថ្ងៃ
______ សៀវភៅអាន
______ រូបកូនសត្វតុក្កតា

*កុំភ្លេចសរសេរឈ្មោះរបស់អ្នក និងឈ្មោះសាលារៀនរបស់អ្នកលើរបស់ប្រើប្រាស់ទាំងអស់។

**មន្ទីរអប់រំ LBUSD និង YMCA CAMP OAKES គ្មានទំនួលខុសត្រូវទេចំពោះរបស់ប្រើប្រាស់ ដែលបានបាត់បង់ ឬមានមនុស្សផ្សេងលួចលាក់យក។ យើងនឹងព្យាយាមធ្វើត្រឡប់ជូនម្ចាស់ដើមវិញអំពីរបស់ប្រើប្រាស់ទាំងឡាយណា ដែលបានរកឃើញមកវិញ។**